ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ....០៤៥៨.........អពដ

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង
## ស្តីពីការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស ដែលបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥

អនុលោមតាមមាត្រា ១១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជានិយោជក និងនិយោជិត ទាំងអស់ជ្រាបថា មាត្រា ៤៧ នៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ត្រូវបានកែប្រែដូចខាងក្រោម÷

មាត្រា ៤៧.- ថ្មី

សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងត្រូវកាត់ទុកដោយនិយោជកតាមអត្រាកំណើនតាមថ្នាក់ ដូចតទៅ÷

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | អត្រាពន្ធ |
|---|---|
| ពី ០៛ ដល់ ៨០០ ០០០៛ | 0% |
| ពី ៨០០ ០០១៛ ដល់ ១ ២៥០ ០០០៛ | ៥% |
| ពី ១ ២៥០ ០០១៛ ដល់ ៨ ៥០០ ០០០៛ | ១០% |
| ពី ៨ ៥០០ ០០១៛ ដល់ ១២ ៥០០ ០០០៛ | ១៥% |
| លើសពី ១២ ៥០០ ០០០៛ | ២០% |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រីជានិយោជក និងនិយោជិតទាំងអស់ ជ្រាបនិងអនុវត្តតាមខ្លឹមសារនៃមាត្រា ៤៧.- ថ្មី ដូចបានជម្រាបជូនខាងលើ សម្រាប់ការប្រកាសពន្ធចាប់ពីខែ មករា ឆ្នាំ២០១៥ នេះតទៅ ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមជឿជាក់ថា លោក-លោកស្រីជានិយោជក និងនិយោជិតទាំងអស់ពិតជាយកចិត្តទុកដាក់គោរពកាតព្វកិច្ចពន្ធ និងអញ្ជើញមកដាក់លិខិតប្រកាសនិងបង់ពន្ធលើប្រាក់បៀវត្សតាមច្បាប់កំណត់។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល